ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្មចិញ្ចឹមជ្រូកកណ្តុរ





រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**

ខែមីនា ឆ្នាំ២០២៤

023 220 811
023 220 810
095 416 878
#9-13, Street 7, Chaktomuk, Daun Penh, Phnom Penh | info@ardb.com.kh | www.ardb.com.kh

## មាតិកា

**១-សេចក្តីផ្តើម** ................................................ ១
**២-លក្ខណៈទូទៅ** ................................................ ១
**៣-បច្ចេកទេសចិញ្ចឹម** ................................................ ១
៣-១-ការជ្រើសរើសមេបាពូជ ................................................ ១
៣-២-វិធីសាស្ត្រចិញ្ចឹម ................................................ ២
៣-៣-ការរៀបចំទ្រុង ................................................ ២
៣-៤-ការផ្តល់ទឹក និងចំណី ................................................ ២
៣-៥-ការថែទាំសុខភាពមេជ្រូក ................................................ ៣
៣-៦-ការថែទាំសុខភាពកូនជ្រូក ................................................ ៤
៣-៧-ការធ្វើប្រព័ន្ធជីវៈសុវត្ថិភាព ................................................ ៤
៣-៨-តម្លៃ និងទីផ្សារ ................................................ ៤
**៤-គម្រោងអាជីវកម្មចិញ្ចឹមជ្រូកកណ្តុរយកកូន** ................................................ ៤
៤-១-គម្រោងចិញ្ចឹម ................................................ ៤
៤-២-ចំណាយលម្អិតលើការចាប់ផ្តើមអាជីវកម្មដំបូង ................................................ ៥
៤-៣-ការវិភាគសេដ្ឋកិច្ច ................................................ ៦
៤-៤-ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់ ................................................ ៨
**៥-ហានិភ័យ វិធានការ និងអនុសាសន៍** ................................................ ៨
**៦-សេចក្តីសន្និដ្ឋាន** ................................................ ១០

## ១-សេចក្តីផ្តើម

ជ្រូកកណ្តុរជាពូជជ្រូកមួយក្នុងចំណោមពូជជ្រូកខ្មែរជាច្រើន។ ពូជនេះងាយស្រួលចិញ្ចឹម ងាយឱ្យចំណី ធន់នឹងជំងឺ ផ្តល់កូនបានច្រើន និងពេញនិយមខ្លាំងសម្រាប់ធ្វើជាជ្រូកខ្វៃ មានរសជាតិឆ្ងាញ់ តែការធំធាត់យឺតជាងពូជជ្រូកផ្សេងៗ។ ទោះបីតម្លៃជ្រូកសាច់មានការប្រែប្រួលយ៉ាងណាក៏ដោយ តែពូជជ្រូកកណ្តុរចិញ្ចឹមយកកូនដើម្បីផ្គត់ផ្គង់ជាជ្រូកខ្វៃមិនសូវប្រែប្រួលឡើយ គឺមិនមានការខាតបង់នោះទេ។ កសិករដែលមានទីធ្លាធំទូលាយ សម្បូរកាកសំណល់ផ្ទះបាយ និងចំណីរួមផ្សំផ្សេងៗអាចបង្កើតកសិដ្ឋានចិញ្ចឹមជ្រូកកណ្តុរនេះបាន ដើម្បីរកចំណូលដោះស្រាយជីវភាពគ្រួសារប្រចាំថ្ងៃ។

ដើម្បីចិញ្ចឹមជ្រូកកណ្តុរទទួលបានកូនច្រើន មានសុខភាពល្អ និងអត្រារស់ខ្ពស់ កសិករគួរអនុវត្តន៍តាមបច្ចេកទេសថ្មីៗមួយចំនួនស្របទៅនឹងស្ថានភាពនៃបម្រែបម្រួលអាកាសធាតុ។ ក្នុងការចិញ្ចឹម កសិករត្រូវគិតគូពីការរៀបចំទ្រុង ការជ្រើសរើសពូជ ការបង្កាត់ពូជ ការថែទាំ និងការផ្តល់ចំណី ដោយព្យាយាមអនុវត្តន៍តាមលំដាប់លំដោយបច្ចេកទេសចាំបាច់ ។

## ២-លក្ខណៈទូទៅ

ជ្រូកកណ្តុរមានខ្លួនខ្លី ខ្នងអែន ពោះធំ ក្បាលដូចកណ្តុរ ច្រមុះស្រួច ចិញ្ចឹម១ឆ្នាំអាចទទួលបានទម្ងន់ជាមធ្យម៦០គ.ក្រ។ ជ្រូកកណ្តុរមានសមត្ថភាពបង្កកំណើតខ្ពស់ មេជ្រូកអាចផ្តល់កូនបានពី២-២.២ដង/ឆ្នាំ។

**-ការផ្តល់ទិន្នផល÷**មេជ្រូកមួយក្បាលអាចផ្តល់កូនពី ៨ ទៅ១២ក្បាល មេខ្លះអាចផ្តល់កូនពី ១៤-២៤ ក្បាល/ ដង។

**-ការសម្របខ្លួន÷**ពូជជ្រូកកណ្តុរអាចសម្របខ្លួនបានល្អទៅនឹងអាកាសធាតុក្នុងស្រុក។ ប្រសិនមានទីធ្លាទូលាយ សម្បូរកាកសំណល់ផ្ទះបាយ និងរុក្ខជាតិបៃតង នោះជ្រូកនឹងងាយស្រួលក្នុងការរស់នៅ ផ្តល់ទិន្នផលខ្ពស់ផងដែរ។

## ៣-បច្ចេកទេសចិញ្ចឹម

### ៣-១-ការជ្រើសរើសមេបាពូជ

ក-មេជ្រូកពូជសម្រាប់ចិញ្ចឹមយកកូនត្រូវមាន÷

-សុខភាពល្អ មិនធ្លាប់មានជំងឺ

-អាយុចាប់ពី៦ខែឡើង និងមិនលើសពី៣ឆ្នាំ

-មានដោះ៦គូឡើង ក្បាលដោះល្អ មិនខ្វាក់ ចន្លោះដោះពីមួយគូទៅមួយគូ ស្មើៗគ្នា

-ចេះចិញ្ចឹមកូន សម្បូរទឹកដោះ។

ខ-<u>បាជ្រូកពូជសម្រាប់បង្កាត់មេ</u>÷

-មានសុខភាពល្អ រាងកាយមាំមួន

-អាយុចាប់ពី៩ខែឡើង និងមិនលើសពី៣ឆ្នាំ

-ពូកែពាក់មេ ស្លូត មិនបង្កគ្រោះថ្នាក់ដល់ម្ចាស់ និងមនុស្សជុំវិញខ្លួន

-មិនរើសចំណី មិនជាន់ឈាម មានកែវភ្នែកភ្លឺថ្លា។

## ៣-២-វិធីសាស្ត្រចិញ្ចឹម

វិធីសាស្ត្រនៃការចិញ្ចឹមមេជ្រូកកណ្តុរយកកូនគឺអាស្រ័យទៅលើស្ថានភាព ទីតាំងភូមិសាស្ត្រដោយការចិញ្ចឹមមានលក្ខណៈខុសៗគ្នា÷

- ការចិញ្ចឹមបែបប្រពៃណីយថាផល÷ ដោយផ្តល់ចំណីដូចជា កាកសំណល់ផ្ទះបាយ កន្ទក់ និងចុងអង្ករដែលមានស្រាប់ក្នុងផ្ទះ ពុំមានការប្រើប្រាស់ថ្នាំ វ៉ាក់សាំង ទៅតាមដំណាក់កាលអាយុជ្រូក។
- ការចិញ្ចឹមបែបលក្ខណៈគ្រួសារ÷ ដោយផ្តល់ចំណី កាកសំណល់ផ្ទះបាយ វត្ថុធាតុដើមក្នុងតំបន់ និងចំណីក្រុមហ៊ុនបន្តិចបន្តួចផងដែរ មានការប្រើប្រាស់ថ្នាំ និងវ៉ាក់សាំងខ្លះៗ។

## ៣-៣-ការរៀបចំទ្រុង

**-<u>កម្រាលទ្រុង</u>**÷ មានផ្ទៃរាបស្មើ រឹងមាំ (មិនឱ្យរលោងពេក ជៀសវាងជ្រូករអិល)។ កម្រាលគួរតែធ្វើឱ្យទេរបន្តិចទៅផ្នែកខាងក្រោយ ងាយស្រួលលាងសម្អាត និងមានកន្លែងបង្ហូរលាមកចេញពីទ្រុង។

**-<u>ដំបូល</u>**÷អាចធ្វើពី ស្បូវ ស្លឹកត្នោត ស័ង្កសី ក្បឿង។ល។ ដំបូលដែលប្រក់ស្បូវឬស្លឹកត្នោត គឺមានតម្លៃថោក និងត្រជាក់ល្អ។




## ៣-៤-ការផ្តល់ចំណី និងទឹក

-**ការផ្តល់ចំណី**÷ចំណីចាំបាច់ត្រូវមានប្រូតេអ៊ីន សារធាតុរ៉ែ និងវីតាមីនគ្រប់គ្រាន់។ ក្នុងផលិតកម្មជ្រូក ការចំណាយទៅលើចំណីមានប្រហែលពី ៧៥ ទៅ ៨០% ក្នុងនេះប្រភេទចំណីសម្រាប់សត្វជ្រូកមាន÷ កន្ទក់ ចុងអង្ករ ពោត សណ្តែក ត្រកួន ចកបាយទា កំប្លោក កន្ទិថេត ផ្ទី ស្លឹកដំឡូងជ្វា ដំឡូងមី ស្លឹកបាស ស្លឹកម្រុំ ដើម និងស្លឹកត្រាវ កំពិស កូនត្រីតូចៗ ក្បាលត្រី សំណល់ផ្ទះបាយ កាកស្រាបៀ។ល។

-**ការផ្តល់ទឹក**÷ ជ្រូកត្រូវការទឹកដើម្បីអាចថែរក្សាសីតុណ្ហភាពនៅក្នុងខ្លួនឱ្យមានតុល្យភាព។ ប្រសិនជ្រូកផឹកទឹកមិនបានគ្រប់គ្រាន់ បណ្តាលឱ្យសីតុណ្ហភាពនៅក្នុងខ្លួនកើនឡើង ស្រេស ការរំលាយអាហារ ការស្រូបយកប្រូតេអ៊ីន និងសារធាតុចិញ្ចឹមក្នុងអាហារមិនបានល្អ ថែមទាំងអាចបណ្តាលឱ្យស្លាប់ផងដែរ។ ការផ្តល់ទឹកប្រកបដោយគុណភាពមានសារៈសំខាន់ណាស់ដូចជា ជួយឱ្យជ្រូកស៊ីចំណីបានច្រើន ធំធាត់លឿន។



## ៣-៥-ការថែទាំសុខភាពមេជ្រូក

ការថែទាំ និងការផ្តល់ចំណីឱ្យបានត្រឹមត្រូវដល់មេជ្រូកពេលមានគភ៌គឺមានសារសំខាន់ណាស់ ហើយក៏អាចរក្សាកូនបានគង់វង្សល្អ÷

- មេជ្រូកដែលបង្កាត់ហើយក្នុងរយៈពេលពី ១-១៦ថ្ងៃដំបូង ក្នុងករណីសីតុណ្ហភាព និងសំណើមខ្ពស់អាចធ្វើឱ្យអត្រាផ្តល់កូនបានតិច
- កន្លែងមេបង្កើតកូនត្រូវមានអាកាសធាតុសមស្រប មានខ្យល់ចេញចូលល្អ និងមានសភាពស្ងប់ស្ងាត់។
- សីតុណ្ហភាពក្តៅស្អុះស្អាប់ធ្វើឱ្យមេជ្រូកពិបាកដកដង្ហើម និងពិបាកក្នុងការបញ្ចេញកម្លាំងបង្កើតកូន បណ្តាលឱ្យការបង្កើតមានសភាពយឺតយ៉ាវអាចបណ្តាលឱ្យថប់ដង្ហើមកូន។

### ៣-៦-ការថែទាំសុខភាពកូនជ្រូក

-កូនជ្រូកទើបកើតត្រូវសម្អាតឱ្យស្អាតស្អួត និងត្រូវផ្តល់ភាពកក់ក្តៅដើម្បីថែរក្សាកូនជ្រូកឱ្យមានសុខភាពល្អ ចៀសវាងជំងឺរាគ និងការពារកូនជ្រូកដែលខ្សោយឱ្យរួចផុតពីសេចក្តីស្លាប់

-គួរផ្តល់កម្តៅចន្លោះពី ៣៤ ទៅ ៣៨អង្សាសេ សម្រាប់កូនជ្រូកទើបកើតបាន៤ថ្ងៃដំបូង

-មេជ្រូកត្រូវមានទឹកដោះគ្រប់គ្រាន់ឱ្យកូនបៅ

-ត្រូវប្រុងប្រយ័ត្ន ជាពិសេសនៅពេលអាកាសធាតុចុះត្រជាក់ខ្លាំងដែលធ្វើឱ្យកូនជ្រូកបាត់បង់ថាមពល និងចុះខ្សោយ។

### ៣-៧-ការធ្វើប្រព័ន្ធជីវសុវត្ថិភាព

មិនគួរអនុញ្ញាតឱ្យអ្នកដទៃចូលក្នុងកសិដ្ឋានឬទ្រុងជ្រូក។ ក្នុងករណីចាំបាច់ មុនពេលចូលគឺត្រូវសម្អាតកាយ និងផ្លាស់ប្តូរសម្លៀកបំពាក់ដែលមាននៅក្នុងកសិដ្ឋាន ឬខោអាវដែលបានសម្លាប់មេរោគត្រឹមត្រូវ។

### ៣-៨-តម្លៃ និងទីផ្សារ

**តម្លៃ**÷ ជាធម្មតាកសិករលក់ឱ្យឈ្មួញប្រមូលទិញក្នុងតម្លៃខាងក្រោមនេះ ÷

-ទម្ងន់ចាប់ពី៧គ.ក្រ ទៅ៩គ.ក្រ តម្លៃ២៥០,០០០រៀល/ក្បាល

-ទម្ងន់ចាប់ពី១០គ.ក្រ ទៅ១២គ.ក្រ តម្លៃ ៣០០,០០០រៀល/ក្បាល

-ទម្ងន់ចាប់ពី១២គ.ក្រ ទៅ១៥គ.ក្រ តម្លៃ ៣៥០,០០០រៀល/ក្បាល

**ទីផ្សារ**÷ លក់កូនជ្រូកកណ្តុររស់ទៅឱ្យកសិករផ្សេងចិញ្ចឹមបន្ត ឬឈ្មួញកណ្តាលយកទៅខ្មែរលក់។

## ៤-គម្រោងអាជីវកម្មចិញ្ចឹមជ្រូកកណ្តុរយកកូន

**៤-១-គម្រោងចិញ្ចឹម**÷ កសិដ្ឋានចិញ្ចឹមជ្រូកកណ្តុរ នៅសង្កាត់សៀមរាប ក្រុងសៀមរាប

-ទំហំដី ÷ ៥,០០០ម៉ែត្រការ៉េ

-ទំហំ រោងជ្រូក ÷ ទទឹង៣ម៉ែត្រ បណ្តោយ១២ម៉ែត្រ ចំនួន៤ខ្នង

-ចំនួនមេជ្រូក ÷ ៣០ក្បាល តម្លៃ ១,២០០,០០០រៀល/ក្បាល

-ចំនួនជ្រូកបា ÷ ២ក្បាល តម្លៃ ១,២០០,០០០រៀល/ក្បាល

-ប្រភពពូជ ÷ ជ្រើសរើសពីមេបាពូជ ដែលគ្មានប្រវត្តិជំងឺពីខេត្តឧត្តរមានជ័យ

-រយៈពេលចិញ្ចឹម÷ ១ឆ្នាំ (ផ្តល់កូនបាន ២លើក/ឆ្នាំ)

-ចំណីមេបា ÷ ប្រើប្រាស់កន្ទក់ សំបកហៃប៊ី ចេក ស្មៅអ៊ីស្រាអែល ត្រកួន និងបន្លែផ្សេងៗ

-ចំណីកូនជ្រូក ÷ ប្រើកន្ទក់ សំបកហៃប៊ី ត្រកួន ចេក និងស្មៅអ៊ីស្រាអែល

-ទិន្នផលកូនជ្រូក÷ ជាមធ្យមចន្លោះពី ៤៥០- ៥១០ក្បាល/ឆ្នាំ

-អត្រារស់ ÷ កូនជ្រូកកើតមករហូតដល់លក់មានអត្រារស់ ៧៥% ទៅ ៨៥%

-តម្លៃទីផ្សារ ÷ ចន្លោះពី ២៥០,០០០៛ ទៅ ៣២០,០០០៛/ក្បាល អាស្រ័យលើទម្ងន់

-តម្រូវការទុន ÷ សម្រាប់ចាប់ផ្តើមអាជីវកម្មដំបូង រួមទាំងការសាងសង់ទ្រុង មេបាពូជ និងសម្ភារៈផ្សេង (មិនរាប់បញ្ចូលថ្លៃដីទីតាំង) ត្រូវចំណាយដើមទុនប្រមាណ **១២១,៨៨៣,០០០រៀល** ក្នុងនោះ÷

| **ទុនវិនិយោគសាងសង់រោង មេបាពូជ និងសម្ភារៈផ្សេងៗ** | **ទុនសម្រាប់ចិញ្ចឹម-ថែទាំក្នុង១ឆ្នាំ (រៀល)** | **ទឹកប្រាក់សរុប (រៀល)** |
|---|---|---|
| **65,243,000** | **56,640,000** | **121,883,000** |

## ៤-២-ចំណាយលម្អិតលើការចាប់ផ្តើមអាជីវកម្មដំបូង ÷

| **ល.រ** | **បរិយាយ** | **ឯកត្តា** | **ចំនួនឯកត្តា** | **តម្លៃ១ឯកត្តា** | **តម្លៃសរុប (រៀល)** | **ចំនួនសាររំលស់** | **ទឹកប្រាក់សរុប (រៀល)** |
|---|---|---|---|---|---|---|---|
| **ក.ចំណាយប្រែប្រួល** | | | | | **56,640,000** | | |
| ១ | ចំណី (កន្ទក់) | គ.ក្រ | 30,080 | 1,150 | 34,592,000 | | |
| ២ | ចំណី (ចេកទុំ) | ស្និត | 3,650 | 500 | 1,825,000 | | |
| ៣ | ចំណី (កន្ទំថេទ ស្មៅអ៊ីស្រាអែល) | គ.ក្រ | 3,650 | 300 | 1,095,000 | | |
| ៤ | សម្បកហៃបី | គ.ក្រ | 180 | 1,400 | 252,000 | | |
| ៥ | ថ្លៃអគ្គិសនី | ខែ | 1,200 | 730 | 876,000 | | |
| ៦ | ថ្នាំនិងវិតាមីនលើមេបា | ខែ | 12 | 80,000 | 960,000 | | |
| ៧ | កម្លាំងពលកម្ម | ខែ | 12 | 1,200,000 | 14,400,000 | | |
| ៨ | ថ្នាំទម្លាក់សត្វល្អិតមេបា | កញ្ចប់ | 12 | 40,000 | 480,000 | | |
| ៩ | ថ្នាំសម្លាប់មេរោគ | ដប | 48 | 20,000 | 960,000 | | |
| ១០ | ដឹកជញ្ជូនឱ្យអតិថិជន | លើក | 12 | 100,000 | 1,200,000 | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ខ.ចំណាយមិនប្រែប្រួល/ថេរ** | | | | | **65,243,000** | | **15,994,167** |
| ១ | រោងជ្រូក (៣ម៉ែត្រ x ១២ម៉ែត្រ) ប្រើប្រាស់បាន ១០ ឆ្នាំ | រោង | 4 | 6,000,000 | 24,000,000 | 10 | 2,400,000 |
| ២ | សំណាញ់ព័ទ្ធជុំវិញបរិមាណរោង | គ.ក្រ | 90 | 3,500 | 315,000 | 10 | 31,500 |
| ៣ | ស្នូកទឹក | ចំនួន | 35 | 20,000 | 700,000 | 5 | 140,000 |
| ៤ | ទុយោរទឹក | ដុំ | 2 | 320,000 | 640,000 | 5 | 128,000 |
| ៥ | ម៉ូទ័របូមទឹក | គ្រឿង | 1 | 200,000 | 200,000 | 3 | 66,667 |
| ៦ | ស្នូកចំណី | ចំនួន | 35 | 20,000 | 700,000 | 5 | 140,000 |
| ៧ | អំពូលកម្តៅ | ចំនួន | 48 | 6,000 | 288,000 | 1 | 288,000 |
| ៨ | មេជ្រូក | ក្បាល | 30 | 1,200,000 | 36,000,000 | 3 | 12,000,000 |
| ៩ | បាជ្រូក | ក្បាល | 2 | 1,200,000 | 2,400,000 | 3 | 800,000 |
| **គ.ចំណាយសរុប=ចំណាយប្រែប្រួល+ចំណាយមិនប្រែប្រួល** | | | | | **121,883,000** | | |

## ៤-៣-ការវិភាគសេដ្ឋកិច្ច÷លើការចិញ្ចឹមមេជ្រូកយកកូនក្នុងរយៈពេល១ឆ្នាំរបស់កសិករនៅភូមិអារញ្ញ សង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប

សម្រាប់ការចិញ្ចឹមមេជ្រូកកណ្តុរយកកូនលក់ (មេជ្រូកចំនួន៣០ក្បាល បា២ក្បាល) ដោយគិតលើទិន្នផលរយៈពេល១ឆ្នាំ លទ្ធផលក្រោយកាត់រំលស់លើចំណាយថេរ និងចំណាយលើការផលិត÷

| ល.រ | បរិយាយ | ឯកត្តា | ចំនួនឯកត្តា | តម្លៃ១ឯកត្តា | តម្លៃសរុប (រៀល) | ចំនួនសាររំលស់ | ទឹកប្រាក់សរុប (រៀល) |
|---|---|---|---|---|---|---|---|
| **១-ចំណូលសរុប/ឆ្នាំ** | | | | | | | **120,000,000** |
| ចំណូលពីការលក់កូនជ្រូក (អាយុ២ខែ) | | ក្បាល | 480 | 250,000 | 120,000,000 | | 120,000,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | | **72,634,167** |
| **ក.ចំណាយប្រែប្រួល** | | | | | | | **56,640,000** |
| ១ | ចំណី (កន្ទក់) | គ.ក្រ | 30,080 | 1,150 | 34,592,000 | | 34,592,000 |
| ២ | ចំណី (ចេកទុំ) | ស្និត | 3,650 | 500 | 1,825,000 | | 1,825,000 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | ចំណី (កន្ទិថេទ ស្ងៅអ៊ីស្រាអែល) | គ.ក្រ | 3,650 | 300 | 1,095,000 | | 1,095,000 |
| ៤ | សម្បកហៃប៊ី | គ.ក្រ | 180 | 1,400 | 252,000 | | 252,000 |
| ៥ | ថ្លៃអគ្គិសនី | ខែ | 1,200 | 730 | 876,000 | | 876,000 |
| ៦ | ថ្នាំនិងវិតាមីនលើមេបា | ខែ | 12 | 80,000 | 960,000 | | 960,000 |
| ៧ | កម្លាំងពលកម្ម | ខែ | 12 | 1,200,000 | 14,400,000 | | 14,400,000 |
| ៨ | ថ្នាំទម្លាក់សត្វល្អិតមេបា | កញ្ចប់ | 12 | 40,000 | 480,000 | | 480,000 |
| ៩ | ថ្នាំសម្លាប់មេរោគ | ដប | 48 | 20,000 | 960,000 | | 960,000 |
| ១០ | ដឹកជញ្ជូនឱ្យអតិថិជន | លើក | 12 | 100,000 | 1,200,000 | | 1,200,000 |
| **ខ.ចំណាយមិនប្រែប្រួល/ថេរ (ក្នុង១ឆ្នាំ)** | | | | | **65,243,000** | | **15,994,167** |
| ១ | រោងជ្រូក (៣ម៉ែត្រ x ១២ម៉ែត្រ) ប្រើប្រាស់បាន ១០ ឆ្នាំ | រោង | 4 | 6,000,000 | 24,000,000 | 10 | 2,400,000 |
| ២ | សំណាញ់ព័ទ្ធជុំវិញបរិមាណរោង | គ.ក្រ | 90 | 3,500 | 315,000 | 10 | 31,500 |
| ៣ | ស្នូកទឹក | ចំនួន | 35 | 20,000 | 700,000 | 5 | 140,000 |
| ៤ | ទុយោទឹក | ដុំ | 2 | 320,000 | 640,000 | 5 | 128,000 |
| ៥ | ម៉ូទ័របូមទឹក | គ្រឿង | 1 | 200,000 | 200,000 | 3 | 66,667 |
| ៦ | ស្នូកចំណី | ចំនួន | 35 | 20,000 | 700,000 | 5 | 140,000 |
| ៧ | អំពូលកម្ដៅ | ចំនួន | 48 | 6,000 | 288,000 | 1 | 288,000 |
| ៨ | មេជ្រូក | ក្បាល | 30 | 1,200,000 | 36,000,000 | 3 | 12,000,000 |
| ៩ | បាជ្រូក | ក្បាល | 2 | 1,200,000 | 2,400,000 | 3 | 800,000 |
| **៣-ចំណេញសរុប/ឆ្នាំ** | | | | | | | **47,365,833** |
| **ថ្លៃដើមចំណាយសរុបលើកូនជ្រូកមួយក្បាល= ការចំណាយសរុប/ចំនួនកូនជ្រូកសរុប** | | | | | | | **151,321** |
| **ចំណេញលើកូនជ្រូកមួយក្បាល= ប្រាក់ចំណេញសរុប/ចំនួនកូនជ្រូកសរុប** | | | | | | | **98,679** |
| **ចំណេញក្នុងមួយខែ=ប្រាក់ចំណេញសរុប/១២ខែ** | | | | | | | **3,947,153** |

### ៤-៤- ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់÷

តាមរយៈការសិក្សា កូនជ្រូកអាយុ២ខែ ទម្ងន់ចាប់ពី៧គ.ក្រ ទៅ១០គ.ក្រ តម្លៃទាប២៥០,០០០ រៀល/ក្បាល និងតម្លៃខ្ពស់ ៣០០,០០០រៀល/ក្បាល ឬលើសនេះអាស្រ័យទម្ងន់ជាក់ស្តែង និងរដូវកាលដែលមានតម្រូវការជ្រូកកណ្តុរខ្ពស់លើទីផ្សារ។

| តម្លៃលក់ រៀល/ក្បាល | ទិន្នផល ក្បាល | ចំណូលសរុប រៀល | ចំណាយសរុប រៀល | ចំណេញ-ខាត រៀល | % |
|---|---|---|---|---|---|
| 200,000 | 480 | 96,000,000 | 72,634,167 | 23,365,833 | 32% |
| 230,000 | 480 | 110,400,000 | 72,634,167 | 37,765,833 | 52% |
| 250,000 | 480 | 120,000,000 | 72,634,167 | 47,365,833 | 65% |
| 270,000 | 480 | 129,600,000 | 72,634,167 | 56,965,833 | 78% |
| 300,000 | 480 | 144,000,000 | 72,634,167 | 71,365,833 | 98% |

### ៥-ហានិភ័យ វិធានការ និងអនុសាសន៍÷

តាមរយៈនៃការចុះសិក្សាកសិដ្ឋានចិញ្ចឹមជ្រូកកណ្តុរនៅសង្កាត់សៀមរាប ក្រុងសៀមរាប ខេត្តសៀមរាប ឃើញថាកសិដ្ឋានអាចជួបនូវហានីភ័យមួយចំនួនជាយថាហេតុលើដំណើរការចិញ្ចឹមជ្រូកកណ្តុរដែលនាំឱ្យបង្កផលវិបាក និងប៉ះពាល់ដល់សមត្ថភាពផលិតកម្មរបស់កសិករ ដូចនេះកសិករគួររៀបចំផែនការជាក់លាក់ដើម្បីកាត់បន្ថយ ឬគ្រប់គ្រងលើហានីភ័យបានប្រកបដោយប្រសិទ្ធភាពខ្ពស់។

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាពីហានិភ័យ | វិធានការ និងអនុសាសន៍ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | ជ្រូកធ្លាប់មានជំងឺពីតូច ជាន់ឈាមពីម្ចាស់មុន មេជ្រូកធ្លាប់មានបញ្ហារលោកស្បូន អត្រាកូនរស់ទាប | -ត្រូវជ្រើសរើសមេបាពូជឱ្យបានល្អ<br>-ស្វែងយល់ពីប្រភពបាជ្រូកឱ្យច្បាស់មុនបង្កាត់ ជៀសវាងបាជ្រូកមានជាប់ខ្សែពូជជាមួយមេជ្រូក<br>-ជ្រើសរើសមេបាជ្រូកចេញពីហ្វូងមិនធ្លាប់កើតជំងឺ<br>-គួរជ្រើសរើសមេជ្រូកក្រមុំមកចិញ្ចឹម<br>-ផ្តល់ចំណីគ្រប់គ្រាន់សម្រាប់មេបំបៅដោះកូន |
| | | តម្លៃចំណីមានការកើនឡើង | -ត្រូវស្វែងរកប្រភពចំណីមានតម្លៃទាប<br>-រៀបចំដាំដំណាំបម្រុងមួយចំនួនសម្រាប់បង្ការការខ្វះខាតចំណី |

| | | | |
|---|---|---|---|
| | | | -ប្រមូលបន្ថែចាស់ៗតាមផ្សារ ចំការផ្សេងៗ ដែលមានភាពងាយស្រួល(សម្លាប់មេរោគ)ឱ្យបានត្រឹមត្រូវ |
| ២ | **ហានិភ័យទីផ្សារ** | -តម្លៃប្រែប្រួល ដោយមានការប្រកួតប្រជែងពីប្រទេសជិតខាង តម្លៃចំណីជ្រូកមានការកើនឡើង | -ស្វែងរកដៃគូសហការណ៍មានភាពស្មោះត្រង់<br>-មានហាងជ្រូកខ្វៃចាំទទួលទិញជ្រូកកណ្ដុរ<br>-ភាពផ្គត់ផ្គង់ច្បាស់លាស់<br>-រកទីផ្សារលក់រាយក្នុងតំបន់ទៅអ្នកបរិភោគផ្ទាល់<br>-មានកសិករទទួលទិញទៅធ្វើពូជបន្ត<br>-មានការផ្សព្វផ្សាយឱ្យទូលំទូលាយ<br>-មានភាពស្មោះត្រង់ និងទំនុកចិត្តដល់អតិថិជន |
| ៣ | **ហានិភ័យហិរញ្ញវត្ថុ** | មិនប្រាក់បម្រុងសម្រាប់ទប់ទល់ហេតុការណ៍កើតឡើងដោយចៃដន្យ | -មានផែនការអាជីវកម្មច្បាស់លាស់<br>-មានទុនបម្រុងក្រៅពីទុនវិនិយោគ<br>-កំណត់បរិមាណចិញ្ចឹមទៅតាមទំហំទុន<br>-មានផែនការលក់វិលជុំ ដើម្បីទទួលបានប្រាក់ចំណូលទៀងទាត់ |
| ៤ | **ហានិភ័យបរិស្ថាន** | មានក្លិនស្អុយ និងសម្លេងរំខានប៉ះពាល់ដល់អ្នកជិតខាង | -ជ្រើសរើសទីតាំងដែលឆ្ងាយពីផ្ទះអ្នកជិតខាត<br>-ត្រូវធ្វើអនាម័យសម្អាតទ្រុងជាប្រចាំ និងមានទីស្តុកលាមកជ្រូកឱ្យបានត្រឹមត្រូវ<br>-អាចសង់ជាឡជីវឧស្ម័នសម្រាប់ប្រើប្រាស់ទៀតផង |

## ៦-សេចក្តីសន្និដ្ឋាន

ជ្រូកកណ្តុរជាជ្រូកដែលកសិករពេញនិយមចិញ្ចឹមនៅតាមទីជនបទ និងកសិដ្ឋានជាលក្ខណៈគ្រួសារ ដោយសារសត្វជ្រូកកណ្តុរមានភាពធន់ខ្លាំងទៅនឹងអាកាសធាតុ ជំងឺ ងាយស្រួលចិញ្ចឹម និងផ្តល់ចំណី ព្រមទាំងមានទីផ្សារល្អទាំងបោះដុំ និងលក់រាយសម្រាប់យកទៅធ្វើពូជបន្តឬធ្វើជាជ្រូកខ្វៃ។

តាមការចុះសិក្សាជាក់ស្តែងការចិញ្ចឹមជ្រូកកណ្តុររបស់កសិករនៅខេត្តសៀមរាប ដែលបានចិញ្ចឹមមេជ្រូក៣០ក្បាល បា២ក្បាលសម្រាប់បង្កាត់កូនលក់ គឺអាចទទួលបានកូនជ្រូកជាមធ្យម ៤៨០ក្បាល/ឆ្នាំ តម្លៃជាមធ្យម ២៥០,០០០រៀល/ក្បាល ដោយចំណាយថ្លៃដើមផលិតប្រមាណ ១៥១,៣២១រៀល/ក្បាល ទទួលបានប្រាក់ចំណេញប្រមាណ ៩៨,៦៧៩រៀល/ក្បាល។

ការចិញ្ចឹមជ្រូកកណ្ដុរកសិករអាចទទួលបានប្រាក់ចំណេញប្រមាណ ៤៧លានរៀល/ឆ្នាំ (ប្រាក់ចំណេញអាចច្រើន ឬតិចជាងនេះអាស្រ័យលើអត្រាបាត់បង់ និងការកាត់បន្ថយចំណាយលើចំណីតាមរយៈការដាំដំណាំចំណីជ្រូក និងការប្រមូលបន្លែចាស់ៗនៅតាមផ្សារមកកែច្នៃជាចំណីបន្ថែម។

ដើម្បីទទួលបានប្រាក់ចំណេញច្រើន កសិករគួរគិតគូរលើកត្តាចាំបាច់មួយចំនួនដូចជា÷ ការជ្រើសរើសពូជជ្រូក ការថែទាំ ការធ្វើអនាម័យ និងការធ្វើប្រព័ន្ធជីវសុវត្ថិភាព ប្រភពវត្ថុធាតុដើមសម្រាប់ផ្សំចំណីក្នុងតំបន់ដែលអាចរកបានក្នុងតម្លៃទាប និងមានទីផ្សារផ្គត់ផ្គង់ច្បាស់លាស់។

## ប្រភពនៃការសិក្សាស្រាវជ្រាវ


១/កសិករចិញ្ចឹមជ្រូកកណ្ដុរនៅសង្កាត់សៀមរាម ក្រុងសៀមរាប ខេត្តសៀមរាប

២/បច្ចេកទេសចិញ្ចឹមជ្រូក (អេម អេស អេម អ៊ី កម្ពុជា,២០១១)

៣/ បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ (នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល)